ក្រសួងមហាផ្ទៃ
បណ្ឌិត្យសភានគរបាលកម្ពុជា
លេខ : ០៥២៧ គស.គស.ន.

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# សេចក្ដីសម្រេច
## ស្ដីពី
## ការបង្កើតសញ្ញាសម្គាល់សម្រាប់សិក្ខាកាមជ័យលាភីនៃវគ្គ «ឋានានុក្រមដឹកនាំកម្រិត៣» នៅបណ្ឌិត្យសភានគរបាលកម្ពុជា

### ប្រធានបណ្ឌិត្យសភានគរបាលកម្ពុជា

- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/២០៥៧ ចុះថ្ងៃទី២៦ ខែសីហា ឆ្នាំ២០២៣ ស្ដីពីការតែងតាំងប្រធានបណ្ឌិត្យសភានគរបាលកម្ពុជា
- បានឃើញអនុក្រឹត្យលេខ១០៩អនក្រ.បក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥ ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងមហាផ្ទៃ
- បានឃើញប្រកាសលេខ១០១០៣ប្រ.ក ចុះថ្ងៃទី៥ ខែកញ្ញា ឆ្នាំ២០២៥ ស្ដីពីការបង្កើតសញ្ញាសម្គាល់សម្រាប់គោរមងារ អភិសន្តិបណ្ឌិត សន្តិបណ្ឌិត អ្នកសិក្សាជ័យលាភី និងអ្នកសិក្សាគ្រប់កម្រិតនៃបណ្ឌិត្យសភានគរបាលកម្ពុជា

### សម្រេច

**ប្រការ១.-**

ត្រូវបានបង្កើតសញ្ញាសម្គាល់សម្រាប់សិក្ខាកាមជ័យលាភីនៃវគ្គ «ឋានានុក្រមដឹកនាំកម្រិត៣» នៅបណ្ឌិត្យសភានគរបាលកម្ពុជា សម្រាប់ប្រើជាផ្លូវការ ដូចបានកំណត់ខាងក្រោម៖

១- សញ្ញាសម្គាល់សម្រាប់សិក្ខាកាមជ័យលាភីនៃវគ្គ «ឋានានុក្រមដឹកនាំកម្រិត៣» មានទម្រង់និងអត្ថន័យដូចខាងក្រោម៖

**ក- ទម្រង់**

- មានរូបរាងជាខែលការពារ ពទ្ធទ្រពីខាងក្រោមដោយក្បាច់ភ្ញីទេសពណ៌មាស។ សញ្ញានេះមានទំហំកម្ពស់២,៥ស.ម. និងទទឹង១,៧ស.ម.
- ផ្នែកខាងលើ មានមកុដរាជតម្កល់នៅពីលើខែលការពារ ហើយកំពូលមកុដរាជមានពន្លឺរស្មីដែលរះចែងចាំងពណ៌មាសចំនួន២៥ តំណាងឱ្យរាជធានី ខេត្តទាំង២៥ក្នុងព្រះរាជាណាចក្រកម្ពុជា។
- ផ្នែកកណ្ដាលខាងលើនៃខែលការពារមានរូបព្រះគណេសពាក់កណ្ដាលខ្លួនពណ៌មាស មានផ្ទៃខាងក្រោយពណ៌ពងក្រសារ។
- នៅខាងក្រោមព្រះគណេស មានផ្កាចន្ទន៍ចំនួន៧ ដែលតំណាងឱ្យសាលានគរបាលជាតិចំនួន៧ នៅតាមបណ្ដាខេត្តនៃព្រះរាជាណាចក្រកម្ពុជា។
- នៅខាងក្រោមផ្កាចន្ទន៍ទាំង៧ មានអក្សរកាត់ ឋដ ពណ៌ផ្កាទីន និងលេខរ៉ូម៉ាំង III ពណ៌ក្រហម។
- រីឯផ្នែកខាងក្រោម រំលេចដោយបូមានពណ៌ក្រហមនិងខៀវ ហើយក្នុងផ្ទៃបូមានសរសេរឈ្មោះវគ្គ "វគ្គ.ឋានានុក្រម ដឹកនាំកម្រិត៣" ពណ៌មាស។

**ខ- អត្ថន័យ**

- សន្លឹកក្បាច់ភ្ញីទេស តំណាងឱ្យការរីកចម្រើនលូតលាស់រុងរឿង សម្បូរសប្បាយ
- ពន្លឺចព្វណ្ណរង្សីស្ថិតនៅពីលើគេ តំណាងឱ្យគំនិត ប្រាជ្ញា ស្មារតី

- មកុដរាជ តំណាងឱ្យអំណាចរបស់ព្រះមហាក្សត្រ ដែលផ្តល់ជាម្លប់ដ៏ត្រជាក់ដល់ប្រជានុរាស្ត្រ និងសិទ្ធិអំណាចដល់ស្ថាប័នជាតិ ក្នុងការថែរក្សាការពារសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ និងសុវត្ថិភាពសង្គម នៅក្នុងព្រះរាជាណាចក្រកម្ពុជា
- ខែល តំណាងឱ្យគ្រឿងបិទបាំងការពារគ្រប់មុំទាំងខាងមុខនិងខាងក្រោយ ដែលបង្ហាញលក្ខណៈរឹងមាំនៃកងកម្លាំងនគរបាលជាតិក្នុងការប្រយុទ្ធប្រឆាំង ទប់ស្កាត់រាល់បទល្មើស
- ព្រះគណេស ជាអទិទេពតំណាងឱ្យច្បាប់ បញ្ញា ចំណេះដឹង និងជាអាទិទេពនៃការបំផ្លាញឧបសគ្គ និងអំពើអាក្រក់ទាំងឡាយ។ ក្នុងន័យនេះ ព្រះគណេសតំណាងឱ្យភាពជាអ្នកប្រាជ្ញ ជាបណ្ឌិត ជាអ្នកចេះដឹង អ្នកជួយដល់សត្វទាំងឡាយគ្រប់ទីកន្លែង ដោយប្រកាន់ខ្ជាប់នូវអំពើល្អ សុចរិតភាព ភាពម៉ឺងម៉ាត់ និងហ្មត់ចត់ ព្រមទាំងបង្កើតឱ្យមានភាពសម្បូរុងរឿង វឌ្ឍនភាព និងវិបុលភាព
- បូមានពណ៌ក្រហមនិងខៀវរំលេចវគ្គសិក្សា «វគ្គ.ឋានានុក្រមដឹកនាំកម្រិត៣» ពណ៌មាសនៅចំកណ្តាល តំណាងឱ្យសន្តិសុខ សុវត្ថិភាពសង្គម សុខសន្តិភាព សាមគ្គីភាព ភាតរភាព និងនិរន្តរភាព ព្រមទាំងបង្ហាញពីភាពមោះមុត អង់អាចក្លាហាន ការប្តេជ្ញាចិត្ត និងភាពជាអ្នកដឹកនាំល្អ ក្នុងនាមកងកម្លាំងនគរបាលជាតិ ក្នុងការគ្រប់គ្រង-ដឹកនាំកងកម្លាំងនគរបាលជាតិ។
- ពណ៌មាស តំណាងឱ្យពន្លឺនៃវិជ្ជាអប់រំបញ្ញា ប្រាជ្ញាស្មារតី ភាពឧត្តុង្គឧត្តម សេចក្តីថ្លៃថ្នូរ គុណតម្លៃកងកម្លាំង និងប្រជាពលរដ្ឋទូទាំងប្រទេសកម្ពុជា

២- ពាក្យ «វគ្គ.ឋានានុក្រមដឹកនាំកម្រិត៣» ជាឈ្មោះនៃវគ្គបណ្តុះបណ្តាល ដែលបណ្ឌិត្យសភា ធ្វើការបណ្តុះបណ្តាលដល់សិក្ខាកាមដែលមានឋានៈនាយរងផ្នែកនិងនាយរងប៉ុស្តិ៍នគរបាលរដ្ឋបាលនៃក្រសួងមហាផ្ទៃ។

រូបរាងសញ្ញាសម្គាល់សម្រាប់សិក្ខាកាមជ័យលាភីនៃវគ្គ «ឋានានុក្រមដឹកនាំកម្រិត៣» ដូចមានភ្ជាប់ក្នុងឧបសម្ព័ន្ធនៃសេចក្តីសម្រេចនេះ។

**ប្រការ២ ..**

សញ្ញាសម្គាល់សម្រាប់សិក្ខាកាមជ័យលាភីនៃវគ្គ «ឋានានុក្រមដឹកនាំកម្រិត៣» ត្រូវបានប្រើប្រាស់ដោយបំពាក់ជាប់គម្របហោប៉ៅអាវឬបំពាក់ពីលើហោប៉ៅអាវផ្នែកខាងស្តាំ។

**ប្រការ៣ ..**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងសេចក្តីសម្រេចនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៤ ..**

ប្រធានក្រុមប្រឹក្សាអភិវឌ្ឍន៍គ្រូនគរបាលជាតិ ប្រធានមន្ទីរចាត់ការ នាយកវិទ្យាស្ថានស្រាវជ្រាវវិទ្យាសាស្ត្រនគរបាល នាយកវិទ្យាស្ថានបណ្តុះបណ្តាលវិជ្ជាជីវៈនគរបាល នាយកវិទ្យាស្ថានគ្រប់គ្រងនិងបញ្ជាដឹកនាំ នាយកវិទ្យាស្ថានព័ត៌មានវិទ្យានិងភាសាបរទេស នាយកវិទ្យាស្ថានក្រោយបរិញ្ញាបត្រ ប្រធានមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈមន្ត្រីពន្ធនាគារ ប្រធាននាយកដ្ឋានបណ្តុះបណ្តាល នាយកសាលាមធ្យមវិជ្ជាជីវៈនគរបាល នាយកសាលាមធ្យមបច្ចេកទេស ប្រធានដេប៉ាតឺម៉ង់ធានាគុណភាពអប់រំផ្ទៃក្នុង នាយកសាលានគរបាលជាតិមិត្តភាពកម្ពុជាវៀតណាម ប្រធានក្រុមការងារនានា អ្នកសិក្សាជ័យលាភី និងអ្នកសិក្សាគ្រប់កម្រិត ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះឱ្យមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខា នេះតទៅ។

ថ្ងៃអង្គារ ១៥កើត ខែអស្សុជ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩

ធ្វើនៅដីឥដ្ឋ ថ្ងៃទី ៧ ខែ តុលា ឆ្នាំ២០២៥

**ប្រធានបណ្ឌិត្យសភានគរបាលកម្ពុជា**

នាយឧត្តមសេនីយ៍ សាស្ត្រាចារ្យ **ឯក មនោសែន**

**កន្លែងទទួល :**

-ថ្នាក់ដឹកនាំបណ្ឌិត្យសភានគរបាលកម្ពុជា

-ដូចប្រការ៤

-ឯកសារ កាលប្បវត្តិ

**ឧបសម្ព័ន្ធនៃសេចក្តីសម្រេចលេខ.....០៥២.......ស.ស.រ.**
**ចុះថ្ងៃអង្គារ១៥កើត.ខែអស្សុជ.ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩ ត្រូវនឹងថ្ងៃទី.៧.ខែ.តុលា..ឆ្នាំ២០២៥**
**ស្តីពីការបង្កើតសញ្ញាសម្គាល់សម្រាប់សិក្ខាកាមជ័យលាភីនៃវគ្គ**
**«ហានានុក្រមដឹកនាំកម្រិត៣» នៅបណ្ឌិត្យសភានគរបាលកម្ពុជា។**

**គំរូសញ្ញាសម្គាល់សម្រាប់សិក្ខាកាមជ័យលាភីនៃវគ្គ «ហានានុក្រមដឹកនាំកម្រិត៣»**

